ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែមីនា ឆ្នាំ២០១៥

នៅក្នុងខែមីនា ឆ្នាំ២០១៥នេះ ព្រឹទ្ធសភាបានបំពេញការកិច្ចរបស់ខ្លួនដូចតទៅ:

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា បាន៖**

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី

-បានផ្ញើសំណើសុំប្រទានសិទ្ធិពីព្រះមហាក្សត្រចំនួន៥៣សំណើ

-ទទួលនូវព្រះរាជសារប្រទានសិទ្ធិពីព្រះមហាក្សត្រចំនួន៥៣ព្រះរាជសារ

-ចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៥៣ព្រះរាជក្រឹត្យ ។

**១.២.ឯកឧត្តម សាយ ឈុំ អនុប្រធានទី១ព្រឹទ្ធសភា បាន** :

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភា

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមក្នុងពិធីជូនព្រះរាជដំណើរព្រះករុណា ព្រះមហាក្សត្រ ស្តេចយាងទៅពិនិត្យព្រះរាជសុខភាព នៅទីក្រុងប៉េកាំង

-ដឹកនាំគណៈប្រតិភូព្រឹទ្ធសភាអញ្ជើញចូលជួបសម្តែងការគួរសមនិងសវនាការជាមួយឯកឧត្តម CHOUMMALY SAYASONE ប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីលៀងសាយភោជន៍ជូនគណៈប្រតិភូជាន់ខ្ពស់ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅព្រះបរមរាជវាំង

-អញ្ជើញជាអធិបតីភាពក្នុងពិធីបើកសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយលទ្ធផលគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា គោលដៅទី៣ ការលើកកម្ពស់សមភាពយេនឌ័រ និងការប្រើសិទ្ធិ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

អំណាចដល់ស្ត្រី" ជូនសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ទាំង៨ភូមិភាគ

-អញ្ជើញចុះជួបអាជ្ញាធរខេត្តកំពង់ស្ពឺ និងអាជ្ញាធររាជធានីភ្នំពេញ ដើម្បីស្តាប់របាយការណ៍ស្វែងយល់ពីសភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ នៃការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន និងផ្តល់អនុសាសន៍ដោះស្រាយការងារបញ្ហាប្រឈមមួយចំនួន និងតាមសំណូមពររបស់ប្រជាពលរដ្ឋ

-អញ្ជើញជួបសំណេះសំណាលជាមួយក្រុមនារី ខេត្តកំពង់ស្ពឺក្នុងឱកាសអបអរខួបលើកទី១០៨ ទិវាអន្តរជាតិនារី ០៨ មីនា ឆ្នាំ២០១៩

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៧៥ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភាបាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងាររវាងឯកឧត្តម **សាយ ឈុំ** ប្រធានស្តីទីព្រឹទ្ធសភា ជាមួយឯកឧត្តម CHOUMMALY SAYASONE ប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-អនុញ្ញាតឲ្យគណៈប្រតិភូនារីដឹកនាំដោយ លោកជំទាវ **អ៊ីង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ចូលជួបសម្តែងការគួរសម និងសំណេះសំណាលក្នុងឱកាសអបអរសាទរទិវានារីអន្តរជាតិ ៨មីនា ឆ្នាំ២០១៩

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩៩ច្បាប់។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើកដើម្បី ៖**

ពិនិត្យ និងសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ចំនួន០២ ទៅគណៈកម្មការជំនាញ និងទៅក្នុងរបៀបវារៈប្រជុំពេញអង្គព្រឹទ្ធសភា៖

១.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពី " ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត"

២.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពី" ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ"

៣.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៦ ព្រឹទ្ធសភា សុំដាក់សេចក្តីស្នើ

ច្បាប់ស្តីពី " ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត " ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៦ ព្រឹទ្ធសភា នីតិកាលទី៣

៤.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៦ ព្រឹទ្ធសភា សុំដាក់សេចក្តីស្នើច្បាប់ស្តីពី " ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ "ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៦ ព្រឹទ្ធសភា នីតិកាលទី៣ "

៥.កំណត់កាលបរិច្ឆេទ និងរបៀបវារៈសម័យប្រជុំលើកទី៦ នីតិកាលទី៣ ។

**៣.សម័យប្រជុំពេញអង្គចំនួន០១លើក ដើម្បី៖**

១.ពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពី "ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត "

២.ពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពី"ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ " ។

**៤. គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែមីនានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាម តួនាទីភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

**៤.១. មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងក្រុមតំណាងរាស្ត្រហត្ថលេខីរបស់រដ្ឋសភា ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីស្នើច្បាប់ចំនួន០២ ។

**៤.២. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងបានចំនួន០៩ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយបានចំនួន០៤ករណី តំកល់ទុកមិនចាត់ការចំនួន០១ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធបានចំនួន០៣ករណី ព្រមទាំងបានឆ្លើយតបទៅម្ចាស់បណ្តឹងបានចំនួន០៥ករណី

-ប្រជុំពិនិត្យពិភាក្សាអំពីខ្លឹមសារ និងគោលបំណងទៅទស្សនកិច្ចសិក្សា និងផ្លាស់ប្តូរបទពិសោធន៍ នៅសាធារណរដ្ឋប្រជាមានិតចិន

-ប្រជុំក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជា-ឡាវ ស្តីពីការប្រកាសសមាសភាពសមាជិកក្រុមថ្មី ផ្សព្វផ្សាយលទ្ធផលនៃកិច្ចសហប្រតិបត្តិការងារជាមួយភាគីឡាវ និងលើកទិសដៅការងារបន្ត

-ប្រជុំក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជា-វៀតណាម ដើម្បីពិភាក្សាអំពីការត្រៀមទៅទស្សនកិច្ច និងផ្លាស់ប្តូរបទពិសោធន៍ នៅខេត្តកៀងយ៉ាង សាធារណរដ្ឋសង្គមនិយមវៀតណាម

-ប្រជុំក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជា-បារាំង ស្តីពីការត្រៀមទទួលស្វាគមន៍គណៈប្រតិភូក្រុមមិត្តភាពវៀតណាម-កម្ពុជា និងក្រុមមិត្តភាពវៀតណាម-បារាំង មកចូលរួមពិធីសមោសរនៅព្រឹទ្ធសភា

-ប្រជុំក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដើម្បីពិនិត្យពិភាក្សា អំពីដំណើរទស្សនកិច្ចរបស់គណៈប្រតិភូស្ថានទូតឡាវ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ទៅខេត្តរតនគិរី

-ប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ដើម្បីពិនិត្យឆ្ងងគម្រោងរៀបចំវគ្គបណ្តុះបណ្តាលជូនក្រុមប្រឹក្សាឃុំ-សង្កាត់នៅខេត្តសៀមរាប

-ប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ដើម្បីពិនិត្យលទ្ធផលការរៀបចំវេទិកាថ្នាក់ស្រុកឆ្នាំ២០១៤ និងត្រៀមលក្ខណៈរៀបចំវេទិកាថ្នាក់ស្រុកឆ្នាំ២០១៥

-ប្រជុំក្រុមសមាជិកាព្រឹទ្ធសភា ដើម្បីត្រៀមរៀបចំសិក្ខាសាលារបស់ក្រុមសមាជិកាព្រឹទ្ធ-សភា នៅភូមិភាគទី២ ខេត្តកំពង់ចាម

-ប្រជុំពិភាក្សាការងារស្តីពី " ការត្រួតពិនិត្យគម្រោងធ្វើសិក្ខាសាលារួមគ្នារវាងគណៈកម្មការទី១០ ព្រឹទ្ធសភា និងរដ្ឋសភា "

-ប្រជុំការងារស្តីពី" ការត្រៀមរៀបចំឯកសាររបស់គណៈប្រតិភូក្រុមសភាជាតិAPF និងការត្រៀមខ្លឹមសារដែលពាក់ព័ន្ធនឹងរបៀបវារៈ នៃកិច្ចប្រជុំគណៈកម្មការនយោបាយ នៃសភានិយមភាសាបារាំង

-ប្រជុំពិគ្រោះយោបល់ពាក់ព័ន្ធនឹងសំណើសុំដាក់គម្រោងផែនការប្រតិបត្តិរបស់គណៈកម្មការទី១០ ចូលក្នុងរបៀបវារៈប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-រៀបចំសិក្ខាសាលាស្តីពី " ការការត្រួតពិនិត្យថ្នាំជក់ " និងស្តីពី " ទស្សនភូមិសាស្ត្រនយោបាយ និងវិស័យការទូតសភា "

-ចូលរួមសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៥ លើប្រធានបទសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ និងតទៅអនាគតស្តីពីកំណែទំរង់ និងសន្និសីទសម្រាប់សភាអាស៊ីប៉ាស៊ីហ្វិក ស្តីពីការប្រែក្លាយការប្តេជ្ញាចិត្តផ្នែកសិទ្ធិមនុស្សអន្តរជាតិទៅជាការអនុវត្តជាក់ស្តែងនៅតាមបណ្តាប្រទេសនានា

-ធ្វើបទបង្ហាញស្តីពី" រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា " ជូនសាស្ត្រចារ្យ និង

និស្សិតនៃវិទ្យាស្ថានអន្តរជាតិកម្ពុជា-អាស៊ាន ចំនួន៩០នាក់

-ចូលរួមស្តាប់បទបង្ហាញស្តីពី " បទពិសោធន៍ និងបញ្ហាប្រឈមទាក់ទងប្រព័ន្ធ និងសេវារបស់សភាស៊ីស " និង"ការផ្សព្វផ្សាយផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង

-បានដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមរបស់ប្រទេសបារាំងចុះទៅព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋ នៅស្រុកសាលាក្រៅ ខេត្តប៉ៃលិន

-ជួបពិភាក្សាការងារជាមួយទីប្រឹក្សាគម្រោង GIZ គាំទ្រស្ថាប័នសវនកម្មកំពូល នៃប្រទេសអាស៊ាន (GIZ-ASEANSA) ដើម្បីពិនិត្យ និងពិភាក្សាអំពីគម្រោងរៀបចំកិច្ចប្រជុំពិភាក្សាអំពី " ទ្រឹស្តីនៃពន្ធ "

-ជួបពិភាក្សាការងារជាមួយលោក ដារ៉ារិទ្ធ គឹមយាត នាយកប្រតិបត្តិវិទ្យាស្ថានសភាកម្ពុជា

-ជួបពិភាក្សាការងារជាមួយ ឯកឧត្តមឯកអគ្គរដ្ឋទូតឡាវ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-ជួបពិភាក្សាការងារជាមួយឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពសហព័ន្ធរុស្ស៊ីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា អំពីគម្រោងរៀបចំទទួលដំណើរទស្សនកិច្ចផ្លូវការរបស់លោកជំទាវ Valentina Matvienko ប្រធានក្រុមប្រឹក្សាសហព័ន្ធ នៃសភាសហព័ន្ធរុស្ស៊ី

-អនុញ្ញាតឲ្យគណៈប្រតិភូយុវជនខេត្តរតនគិរី ដឹកនាំដោយឯកឧត្តម ថន សាវ៉ុន អភិបាលខេត្ត ចូលជួបពិភាក្សាការងារ

-អនុញ្ញាតឲ្យតំណាងអង្គការសិទ្ធិលំនៅដ្ឋាន និងតំណាងសហគមន៍សង្កាត់ព្រែកតាសេក សង្កាត់ព្រែកលៀប និងសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ជួបពិភាក្សាបញ្ហាពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋជាមួយក្រុមហ៊ុន OCIC

-អនុញ្ញាតឲ្យគណៈប្រតិភូជប៉ុនដឹកនាំដោយលោក Toru Hirano managing Director of Koushin Corporation Co.LTD ចូលជួបពិភាក្សាការងារដើម្បីរកឱកាសបណ្តាក់ទុនវិនិយោគនៅកម្ពុជា

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន ១៣៧លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៣៩លើក។

### ៤.៣. មុខងារត្រួតពិនិត្យ

-ជួបសវនាការជាមួយឯកឧត្តមទេសរដ្ឋមន្ត្រី **អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការចុះបញ្ជីដីជាលក្ខណៈប្រព័ន្ធ និងដាច់ដោយដុំ ការផ្តល់ប័ណ្ណកម្មសិទ្ធិលើដីធ្លី និងអចលនទ្រព្យជូនប្រជាពលរដ្ឋ និងលទ្ធផលនៃការដោះស្រាយពាក្យបណ្តឹងដីធ្លីក្នុងឆ្នាំកន្លងមក ។

-ជួបសវនាការជាមួយឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ស្តីពីការប្រើប្រាស់ដោយពេញលេញនូវភោគទ្រព្យ និងធនធានធម្មជាតិរបស់ប្រជាពលរដ្ឋ និងការដោះស្រាយវិវាទដីធ្លីនៅក្នុងស្រុកគិរីសាគរ និងបុទុមសាគរ ខេត្តកោះកុង ។

### ៤.៤. មុខងារព័ត៌មាន

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញចុះស្រាវជ្រាវប្រមូលព័ត៌មាននៅខណ្ឌព្រែកព្នៅ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីត្រៀមលក្ខណៈរៀបចំវេទិកាក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ។

### ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ :

-ឯកឧត្តម **ឈិត គឹមយាត** បានអញ្ជើញចូលរួមពិធីប្រគល់ពានរង្វាន់ជូនដល់សហគ្រាសស្មោះត្រង់អន្តរជាតិលើកទី១៣របស់អាស៊ីប៉ាស៊ីហ្វិក(Keris Award 2014) នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី និងអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួល កិច្ចការនយោបាយរបស់សភាតំបន់អាស៊ី នៅទីក្រុងអង់ការ៉ា ប្រទេសទួគី ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៥

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**តេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ